ជ្រើសតាំងជាទៀងទាត់តាមរយៈការបោះឆ្នោត តាមគំនិតរបស់ប្រជាពលរដ្ឋ។ នៅក្នុងការបោះឆ្នោត យើងម្នាក់ៗមានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ ហើយសន្លឹកឆ្នោតរបស់យើងមានតម្លៃស្មើៗគ្នា។ យើងមិនត្រូវប្រាប់គេពីនរណា ដែលយើងបោះឆ្នោតឱ្យនោះទេ ប្រសិនបើយើងមិនចង់ប្រាប់នោះ។ យើងទាំងអស់គ្នាមានសិទ្ធិដូចគ្នាក្នុងការបម្រើសេវាសាធារណៈ។

## ២២. សន្តិសុខសង្គម

ជាសមាជិកម្នាក់នៅក្នុងសង្គម យើងអាចកសាងជីវិតល្អមួយ សម្រាប់ខ្លួនយើង និងប្រើប្រាស់ឱកាសល្អៗ ដែលសង្គមបានផ្ដល់ឱ្យ ដើម្បីទាញយកប្រយោជន៍ដល់ការរស់នៅរបស់យើង។ ប្រសិនបើមាននរណាម្នាក់ជួបការលំបាក យើងទាំងអស់គ្នាគួរតែរួមគ្នាដើម្បីជួយតាមលទ្ធភាពដែលយើងអាចធ្វើបាន។

## ២៣. ការងារ

យើងទាំងអស់គ្នាគួរតែមានការងារធ្វើ និងអាចជ្រើសរើសការងារដែលយើងចង់ធ្វើដោយសេរី។ យើងត្រូវតែទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់ ដើម្បីយើងអាចគ្រប់គ្រងគ្រួសារយើងបាន ហើយថៅកែគួរតែប្រព្រឹត្តមកលើយើងឱ្យបានល្អ។ ប្រសិនបើយើងបាត់បង់ការងារ រដ្ឋាភិបាលគួរតែជួយយើងរហូតដល់យើងអាចរកការងារមួយទៀតបាន។ ប្រុស និង ស្រីធ្វើការដូចគ្នាគួរតែទទួលបានកម្រៃស្មើគ្នា។ អ្នកធ្វើការទាំងអស់អាចរួបរួមគ្នា ដើម្បីការពារផលប្រយោជន៍របស់ពួកគេ។

## ២៤. ការឈប់សម្រាក

ម៉ោងធ្វើការក្នុងមួយថ្ងៃមិនគួរយូរពេកទេ ដោយសារយើងទាំងអស់គ្នាមានសិទ្ធិឈប់សម្រាក និងគួរទទួលបានប្រាក់កម្រៃទៀងទាត់សម្រាប់ការឈប់សម្រាកនេះ។

## ២៥. តម្រូវការចាំបាច់

យើងទាំងអស់គ្នាគួរតែមានអ្វីគ្រប់គ្រាន់តាមតម្រូវការចាំបាច់របស់យើង និងគ្រួសារយើងដូចជា សេវាសុខភាព អាហារគ្រប់គ្រាន់ សម្លៀកបំពាក់ និងផ្ទះសម្បែង។ យើងគួរតែត្រូវទទួលបានការជួយឧបត្ថម្ភ ប្រសិនបើយើងគ្មានការងារធ្វើ មានជំងឺចាស់ជរា ឬស្លាប់ ឬប្រសិនបើយើងគ្មានលទ្ធភាពចិញ្ចឹមជីវិត ដោយសារអស់ជម្រើស។ មាតា និង ទារក គួរតែទទួលបានការគាំពារពិសេស។ កុមារទាំងអស់ គួរតែត្រូវបានទទួលការរាប់រកដោយស្មើៗគ្នាដោយមិនគិតថាឪពុកម្ដាយរបស់ពួកគេបានរៀបការត្រឹមត្រូវ ឬមិនបានរៀបការនោះទេ។

## ២៦. ការអប់រំ

យើងទាំងអស់គ្នាអាចទទួលបានការរៀនសូត្រ ហើយជាពិសេសក្មេងៗគួរតែទៅសាលារៀន។ គ្មាននរណាម្នាក់តម្រូវឱ្យបង់ប្រាក់ដើម្បីទៅរៀននៅថ្នាក់បឋមសិក្សានោះទេ។ យើងទាំងអស់គ្នា អាចរៀនយកជំនាញណាមួយ ឬបន្តការសិក្សាឱ្យកាន់តែខ្ពស់តាមបំណងប្រាថ្នា។ នៅសាលា យើងអាចបណ្ដុះទេពកោសល្យរបស់យើង ហើយគួរតែរៀនពីសិទ្ធិមនុស្ស និងពីរបៀបក្នុងការរាប់រកគ្នាជាមួយអ្នកដទៃ ទោះជាគេមានពណ៌សម្បុរ សាសនា ឬមកពីប្រទេសផ្សេងទៀតក៏ដោយ។ ឪពុកម្ដាយយើងមានសិទ្ធិជ្រើសរើសអ្វីដែលយើងចង់រៀន និងពីអ្វីដែលយើងអាចរៀនបាន។

## ២៧. វប្បធម៌

យើងទាំងអស់គ្នាអាចចូលរួមក្នុងជីវភាពវប្បធម៌ សហគមន៍ ទទួលផលពីសិល្បៈ និងទទួលបានគុណប្រយោជន៍ពីរបកគំហើញថ្មីៗ ពីវិទ្យាសាស្ត្រ និងពីស្នាដៃល្អៗដែលគេបានធ្វើ។ ប្រសិនបើយើងបង្កើតស្នាដៃអ្វីមួយពិសេសដូចជាសរសេរសៀវភៅ ឬគូរគំនូរ យើងនឹងទទួលបានប្រយោជន៍ពីស្នាដៃទាំងនេះ ហើយគ្មាននរណាម្នាក់ អាចលួចគំនិតស្នាដៃយើងបានឡើយ។

## ២៨. សន្តិភាព

ដូច្នេះ នៅពេលណាយើងទទួលបានសិទ្ធិដូចដែលយើងបានអានកន្លងមកនៅក្នុងសេចក្ដីប្រកាសនេះ មនុស្សទាំងអស់នឹងអាចរស់នៅក្នុងសន្តិភាពទាំងនៅក្នុងសហគមន៍របស់យើង និងរវាងប្រទេសមួយទៅប្រទេសមួយ។

## ២៩. សហគមន៍

យើងទាំងអស់គ្នាអាចចូលរួមចំណែកក្នុងសហគមន៍ដើម្បីធ្វើឱ្យជីវិតយើងកាន់តែប្រសើរ។ ច្បាប់ ត្រូវតែសរសេរឱ្យបានច្បាស់លាស់ថាយើងទាំងអស់គ្នា អាចទទួលបានសិទ្ធិមនុស្សដោយសុខដុមរមនាជាមួយអ្នកដទៃ ។ ច្បាប់ត្រូវធានាឱ្យមនុស្សគ្រប់រូបចេះគោរពគ្នាទៅវិញទៅមក និងធ្វើឱ្យមនុស្សគ្រប់រូបត្រូវតែគោរពច្បាប់។

## ៣០

គ្មាននរណាម្នាក់អាចប្រើសេចក្ដីប្រកាសនេះ ដើម្បីនិយាយដោះសាពីការធ្វើឱ្យខូចខាតដល់សិទ្ធិរបស់អ្នកដទៃ ថាជាការត្រឹមត្រូវ ដោយអះអាងថា ពួកគេគ្រាន់តែព្យាយាមចង់ការពារសិទ្ធិរបស់ខ្លួនតែប៉ុណ្ណោះ។ មិនអាចទទួលយកបានទេ ចំពោះការធ្វើឱ្យខូចខាតដល់សិទ្ធិអ្នកដទៃ។

**ចំណាំ៖** អត្ថបទនេះមិនមែនជាអត្ថបទផ្លូវការរបស់អង្គការសហប្រជាជាតិទេ ហើយក៏មិនមែនជាអត្ថបទដែលត្រូវបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិដែរ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយ គ្រាន់តែសម្រាប់គោលបំណងលើកកម្ពស់ការយល់ដឹងផ្នែកសិទ្ធិមនុស្សដោយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជាតែប៉ុណ្ណោះ។ ក្នុងករណីមិនច្បាស់ត្រង់ចំណុចណាមួយ សូមយោងដល់អត្ថបទជាផ្លូវការនៃសេចក្ដីប្រកាសនេះ។


អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្ដមស្នងការ
កម្ពុជា

សម្រាប់ព័ត៌មានបន្ថែម សូមចូលគេហទំព័រ៖ www.cambodia.ohchr.org
ទូរសព្ទ៖ +855(0) 23 987 671 ឬ +855(0)23 993 590
ទូរសារ៖ +855(0) 23 212 579 ឬ +855(0)23 213 587
@OHCHRCambodia @OHCHR_Cambodia
cambodia@ohchr.org


ខួបគម្រប់ ៧០ ឆ្នាំ
សេចក្ដីប្រកាស
ជាសកល
ស្ដីពីសិទ្ធិមនុស្ស
#STANDUP4HUMANRIGHTS

# សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

នេះគឺជាអត្ថបទដែលធ្វើការកែសម្រួលពីខ្លឹមសារដើម
មកជាពាក្យសម្រាយឱ្យយើងទាំងអស់គ្នាងាយយល់


អត្ថបទប្រែសម្រួលក្រៅផ្លូវការ
**អង្គការសហប្រជាជាតិ**
ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា ២០១៨



អង្គការសហប្រជាជាតិ
អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្ដមស្នងការ
កម្ពុជា

យើងកំពុងប្រារព្ធខួបទី៧០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ក្នុងឆ្នាំ២០១៨ នេះ។ នៅក្នុងសេចក្តីប្រកាសនេះ ប្រទេសទាំងអស់នៅលើពិភពលោកបានរួបរួមគ្នា ហើយបានយល់លើបញ្ហាសំខាន់ៗជាច្រើនដែលយើងទាំងអស់គ្នាជាមនុស្សគួរតែមាន ដើម្បីធ្វើឱ្យយើងអាចរស់នៅដោយសប្បាយរីករាយ។ បញ្ហាទាំងអស់នេះគឺជាសិទ្ធិមនុស្ស របស់យើង។ សិទ្ធិទាំងនេះ គឺជារបស់យើងទាំងអស់គ្នា ពីព្រោះយើងគឺជាមនុស្ស។

សេចក្តីប្រកាសជាសកលនេះ គឺពិសេសណាស់នៅប្រទេសកម្ពុជាដោយសារត្រូវបាន ការពារដោយរដ្ឋធម្មនុញ្ញ។ នេះមានន័យថា យើងទាំងអស់គ្នានៅកម្ពុជាគួរតែមានសិទ្ធិ មនុស្សជាមូលដ្ឋានទាំងនេះ។

ដោយសេចក្តីប្រកាសនេះ ប្រើពាក្យដែលមនុស្សភាគច្រើនពិបាកយល់ ទើបការិយាល័យ នៅកម្ពុជាធ្វើការកែសម្រួលពីខ្លឹមសារដើមមកជាពាក្យសម្រាយដើម្បីធ្វើឱ្យយើងទាំងអស់ គ្នាអាចយល់បាន និងយល់ថាហេតុអ្វីបានជាសេចក្តីប្រកាសនេះសំខាន់។

# សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស

## ១. សេចក្តីថ្លៃថ្នូរ

ចាប់តាំងពីយើងកើតមក យើងមានសេរីភាព និងគួរតែទទួលបានការគោរព រាប់រកដូចគ្នាទៅនឹងមនុស្សដទៃទៀតដែរ។ យើងអាចគិតពិចារណា និង យល់ដឹងដោយខ្លួនយើង ពីអ្វីខុស អ្វីត្រូវ។ យើងគួររាប់រកគ្នា ដោយមិត្តភាព។

## ២. សមភាព

សិទ្ធិនៅក្នុងសេចក្តីប្រកាសនេះ គឺជាសិទ្ធិរបស់យើងទាំងអស់គ្នា៖ ជារបស់ កុមារា កុមារី ជារបស់បុរស និងស្ត្រី។ សិទ្ធិទាំងនេះជារបស់យើងទាំងអស់គ្នា ទោះជាយើងមានពណ៌សម្បុរខុសគ្នាក៏ដោយ។ សិទ្ធិទាំងនេះជារបស់យើង ទាំងអស់គ្នា ទោះជាយើងនិយាយភាសាផ្សេងគ្នាក៏ដោយ ឬមានគំនិត និង ជំនឿ ឬសាសនាផ្សេងគ្នាក៏ដោយ។ សិទ្ធិទាំងនេះជារបស់អ្នកក្រ ក៏ដូចជា របស់អ្នកមាន ជារបស់គ្រួសារធម្មតា ជារបស់គ្រួសារអ្នកមានអំណាច។ សិទ្ធិទាំងនេះជារបស់យើងទាំងអស់គ្នា ទោះជាយើងមកពីប្រទេសផ្សេងគ្នា ដែលជាប្រទេសឯករាជ្យ ឬមិនមានឯករាជ្យក៏ដោយក៏សិទ្ធិទាំងនេះមិនខុស គ្នាដែរ។

## ៣. ជីវិត

យើងទាំងអស់គ្នាមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសិទ្ធិមាន សុវត្ថិភាព។

## ៤. ទាសភាព

គ្មាននរណាម្នាក់ប្រព្រឹត្តមកលើយើងដូចជាទាសករនោះទេ ហើយយើងក៏ មិនត្រូវប្រព្រឹត្តទៅលើនរណាម្នាក់ដូចជាទាសករដែរ។

## ៥. ទារុណកម្ម

គ្មាននរណាម្នាក់ធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើឃោរឃៅ ឬផ្តន្ទាឱ្យយើងបាត់ តម្លៃជាមនុស្សឡើយ។

## ៦. ច្បាប់

ច្បាប់ត្រូវសរសេរឱ្យច្បាស់ថា យើងទាំងអស់គ្នាអាចទាមទារសិទ្ធិមនុស្សរបស់ យើង តាមរយៈច្បាប់ ហើយគ្មាននរណាម្នាក់ត្រូវបានបដិសេធចោលនោះទេ។

## ៧. ច្បាប់

យើងទាំងអស់គ្នាត្រូវបានការពារដោយច្បាប់ តាមវិធីដូចគ្នាដូចអ្នកឯទៀត ដែរ។ ច្បាប់គួរតែដូចៗគ្នា សម្រាប់យើងទាំងអស់គ្នា ហើយគួរត្រូវយកមក អនុវត្តស្មើៗគ្នាចំពោះមនុស្សគ្រប់គ្នា។

## ៨. ច្បាប់

យើងទាំងអស់គ្នា អាចសុំការជួយពីអ្នកដទៃដែលចេះច្បាប់ នៅពេលដែល សិទ្ធិតាមផ្លូវច្បាប់របស់យើងមិនត្រូវបានគោរព។

## ៩. ពន្ធនាគារ ( គុក )

គ្មាននរណាម្នាក់អាចឃាត់ខ្លួនរបស់យើង ឬដាក់យើងនៅក្នុងគុក ឬដេញ យើងចេញទៅប្រទេសមួយទៀត ដោយមិនត្រឹមត្រូវ ឬដោយគ្មានហេតុផល ត្រឹមត្រូវនោះទេ។

## ១០. យុត្តិធម៌

ប្រសិនបើនរណាម្នាក់ចោទយើងថារំលោភច្បាប់ បញ្ហានេះត្រូវលើកយកទៅ កាត់សេចក្តីនៅក្នុងសវនាការមួយ ដែលមានអ្នកដទៃផ្សេងទៀតចូលរួម ស្តាប់។ អ្នកកាត់សេចក្តី មិនគួរឱ្យអ្នកដទៃមកបង្គាប់បញ្ជាទេ គាត់ត្រូវតែ សម្រេចពីអ្វីដែលជាការពិត និងការមិនពិតប៉ុណ្ណោះ។

## ១១. យុត្តិធម៌

ប្រសិនបើយើងត្រូវជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ យើងត្រូវបានចាត់ទុកថា ជាមនុស្សគ្មានទោសរហូតទាល់តែមានភស្តុតាងបង្ហាញនៅក្នុងសវនាការ មួយ ប្រកបដោយភាពយុត្តិធម៌ថាយើងមានកំហុស។ យើងម្នាក់ៗត្រូវបាន អនុញ្ញាត ឱ្យការពារខ្លួនដោយខ្លួនឯង។គ្មាននរណាម្នាក់អាចថ្កោលទោស យើង ឬដាក់ទោសយើងចំពោះអ្វីដែលយើងមិនបានធ្វើនោះទេ។

## ១២. ភាពឯកជន ( រឿងផ្ទាល់ខ្លួន )

គ្មាននរណាម្នាក់ ត្រូវបានអនុញ្ញាតឱ្យនិយាយសំអុយ ឬរឿងមិនពិតអំពី យើង ចូលផ្ទះយើង បើកមើលសំបុត្ររបស់យើង ឬក៏មករំខានយើង ឬ គ្រួសារយើង ដោយគ្មានហេតុផលសមរម្យនោះទេ។

## ១៣. ការដើរហើរ

យើងទាំងអស់គ្នាអាចដើរហើរនៅក្នុងប្រទេសរបស់យើងដោយសេរី។ យើង ក៏អាចចេញទៅក្រៅប្រទេសណាមួយ និងវិលមកប្រទេសយើងវិញបានដែរ ដោយគ្មានការបង្ខំ។

## ១៤. ជនភៀសខ្លួន

ប្រសិនបើនរណាម្នាក់ ព្យាយាមធ្វើបាបយើង យើងអាចរត់ទៅ ប្រទេសមួយទៀត ដើម្បីសុំឱ្យគេការពារ។ ក៏ប៉ុន្តែ យើងមិនអាចរត់គេច ខ្លួនបានទេ ប្រសិនបើខ្លួនយើងផ្ទាល់ បានធ្វើអ្វីខុសដូចជា ធ្វើឱ្យអន្តរាយ ដល់អ្នកដទៃ ឬមិនគោរពសិទ្ធិមនុស្សជាដើម។

## ១៥. សញ្ជាតិ

យើងទាំងអស់គ្នាគួរតែទទួលបានសញ្ជាតិមួយ។ គ្មាននរណាម្នាក់អាច រារាំងយើងមិនឱ្យមានសញ្ជាតិពីប្រទេសរបស់យើង ឬសញ្ជាតិពីប្រទេស ផ្សេងទៀតដែលយើងចង់បានដោយគ្មានហេតុផលសមរម្យឡើយ។

## ១៦. អាពាហ៍ពិពាហ៍

នៅពេលណាដែលយើងដល់អាយុគ្រប់ការ យើងអាចរៀបការ និងកសាង គ្រួសារមួយបាន។ គ្មាននរណាម្នាក់អាចហាមឃាត់មិនឱ្យយើងរៀបការ ដោយសារតែពណ៌សម្បុរ ប្រទេសកំណើត ឬសាសនារបស់យើងឡើយ។ បុរស និង ស្ត្រី មានសិទ្ធិដូចគ្នា នៅពេលដែលពួកគេរៀបការ និងនៅពេល ដែលគេលែងលះគ្នា។ គ្មាននរណាម្នាក់បង្ខំយើងឱ្យរៀបការជាមួយនឹងអ្នក ដែលយើងមិនចង់រៀបការនោះឡើយ។ រដ្ឋាភិបាល និងប្រជាជននៃប្រទេស របស់យើងគួរតែការពារគ្រួសារ និងសមាជិកគ្រួសារយើង។

## ១៧. ទ្រព្យសម្បត្តិ

យើងទាំងអស់គ្នាមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងឡាយ របស់យើង ហើយគ្មាននរណាម្នាក់មានសិទ្ធិលើទ្រព្យសម្បត្តិយើង ដោយ គ្មានហេតុផលសមរម្យនោះទេ។

## ១៨. សាសនា

យើងទាំងអស់គ្នា មានសិទ្ធិជឿលើសាសនារបស់ខ្លួនបានដោយសេរី មាន សិទ្ធិផ្លាស់ប្តូរសាសនា និងគោរពប្រតិបត្តិសាសនានោះ ដោយខ្លួនយើង ផ្ទាល់ ឬជាមួយអ្នកដទៃ។

## ១៩. ការសម្តែងមតិ

យើងទាំងអស់គ្នាអាចគិតពីអ្វីដែលយើងចង់គិត និយាយពីអ្វីដែលយើងចង់ និយាយ ហើយគ្មាននរណាម្នាក់អាចមកហាមឃាត់យើងមិនឱ្យធ្វើដូច្នេះ ឡើយ។ យើងក៏អាចផ្លាស់ប្តូរយោបល់គ្នាជាមួយមនុស្សទាំងអស់នៅក្នុង ប្រទេសយើងក៏ដូចជាមួយប្រជាជននៃប្រទេសផ្សេងទៀតផងដែរ។

## ២០. ការជួបជុំ

យើងទាំងអស់គ្នាអាចជួបប្រជុំគ្នាបានដោយសន្តិវិធី ឬក៏ចូលរួមក្នុងការប្រជុំ ជាមួយអ្នកដទៃដោយសន្តិភាព។ ការបង្ខំនរណាម្នាក់ឱ្យចូលរួមក្នុងក្រុម ណាមួយ គឺជាប្រការមិនត្រឹមត្រូវទេ។

## ២១. ប្រជាធិបតេយ្យ

យើងទាំងអស់គ្នាអាចចូលរួមចាត់ចែងជោគវាសនារបស់ប្រទេសជាតិតាម រយៈការបោះឆ្នោតជ្រើសរើសអ្នកណាដែលយើងពេញចិត្ត ឬក៏ឈរឈ្មោះឱ្យ គេបោះឆ្នោតជ្រើសរើសយើង ធ្វើជាតំណាងរបស់គេ។ រដ្ឋាភិបាលត្រូវបាន